ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៤៩៤ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១០

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យ

Collection by VCAT Professional Consultant

## សម្រេច

**ប្រការ ១.-**

បង្កើត **"គណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ"** ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **គន់ ទិម្មុល** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្តម **ឆាន់ សាផាន** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣. | ឯកឧត្តម **ស៊ីម អៀង** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | ឯកឧត្តម **ចាន់ សុទ្ធុឡ្ស** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥. | ឯកឧត្តម **ជាប ជាចុច** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ នៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិកប្រចាំការ |
| ៦. | លោក **នូច ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានឧស្សាហកម្ម និងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. | លោក **អោម ចន** | អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | លេខាធិការ |

**ប្រការ ២.-**

គណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យមានភារកិច្ច ដូចខាងក្រោម :

- រៀបចំគោលនយោបាយ និងគោលការណ៍សម្រាប់កំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច
- កំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមរាជធានី-ខេត្តនីមួយៗ ហើយដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និងប្រកាសអនុញ្ញាតឱ្យប្រើប្រាស់ ។ ក្នុងករណីចាំបាច់ ការកំណត់តម្លៃអចលនទ្រព្យ ត្រូវមានការចូលរួមផ្តល់យោបល់ពីសមាគមអ្នកវាយតម្លៃអចលនទ្រព្យជាតិកម្ពុជា
- ផ្សព្វផ្សាយ ណែនាំ និងអប់រំជាសាធារណៈ ដល់អនុគណៈកម្មការ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានាស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ



Collection by VCAT Professional Consultant

- ពិនិត្យកែសម្រួលតម្លៃអចលនទ្រព្យ សម្រាប់រយៈពេលកំណត់ណាមួយ តាមការចាំបាច់នៃការប្រែប្រួលថ្លៃអចលនទ្រព្យ
- ចេញសេចក្តីណែនាំ និងសម្របសម្រួលក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន និងត្រួតពិនិត្យការងាររបស់អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យរាជធានី-ខេត្ត ។

**ប្រការ ៣.-**

គណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ មានសិទ្ធិបង្កើតអនុគណៈកម្មការនៅតាមរាជធានី-ខេត្តនីមួយៗ ។ សមាសភាពអនុគណៈកម្មការទាំងនេះគឺជាសមាសភាពរបស់អនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ដែលមានស្រាប់ សម្រាប់ជាជំនួយការក្នុងការអនុវត្តភារកិច្ចខាងលើ ។

អនុគណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម :

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអលចនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមមូលដ្ឋាន ក្នុងដែនសមត្ថកិច្ចរាជធានី-ខេត្ត និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានាស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈ រួមទាំងបិទប្រកាសផ្សាយនៅតាមមូលដ្ឋាន ក្នុងដែនសមត្ថកិច្ចរាជធានី-ខេត្ត
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តរបស់ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ។

**ប្រការ ៤.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យរាជធានី-ខេត្ត មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ជាជំនួយការ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រុមការងារនេះមានភារកិច្ច ដូចតទៅ :

- រួមសហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានាស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យរាជធានី-ខេត្ត



Collection by VCAT Professional Consultant

- ចូលរួមកំណត់អចលនទ្រព្យតាមតំបន់ ប្រភេទ និងទីតាំង ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមសេចក្តីណែនាំរបស់គណៈកម្មការវាយតម្លៃអលចនទ្រព្យ
- ចូលរួមផ្សព្វផ្សាយ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលកំណត់ដោយគណៈកម្មការវាយតម្លៃអលចនទ្រព្យ
- ជួយសហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យ ដល់រដ្ឋបាលសារពើពន្ធ
- ជួយសហការការងារដទៃទៀតជាមួយរដ្ឋបាលសារពើពន្ធតាមការស្នើសុំ ។

**ប្រការ ៥.-**

គណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

**ប្រការ ៦.-**

ឯកឧត្តម អស់លោក ដូចមានរាយនាមក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
  "ដើម្បីជូនជ្រាប"
- សាលារាជធានី-ខេត្ត "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ១ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Collection by VCAT Professional Consultant